ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងការបរទេស
និងសហប្រតិបត្តិការអន្តរជាតិ

**សេចក្តីប្រកាសព័ត៌មាន**

**កម្ពុជា និង សាធារណរដ្ឋកូរ៉េ ជួបពិភាក្សាអំពីកិច្ចសហប្រតិបត្តិការ**

ឯកឧត្តមឧបនាយករដ្ឋមន្ត្រី ប្រាក់ សុខុន រដ្ឋមន្ត្រីការបរទេស និងសហប្រតិបត្តិការអន្តរជាតិ បានជួបពិភាក្សាទ្វេភាគីជាមួយ ឯកឧត្តម ប៉ាក ជីន (Park Jin) រដ្ឋមន្ត្រីការបរទេសនៃសាធារណរដ្ឋកូរ៉េ នៅក្នុងឱកាសនៃកិច្ចប្រជុំរដ្ឋមន្ត្រីការបរទេសអាស៊ាន និងកិច្ចប្រជុំពាក់ព័ន្ធ នៅថ្ងៃទី០៥ ខែសីហា ឆ្នាំ ២០២២ នៅរាជធានីភ្នំពេញ ប្រទេសកម្ពុជា។

រដ្ឋមន្ត្រីការបរទេសទាំងពីរ បានសម្តែងការពេញចិត្តចំពោះការរីកចម្រើនជាបន្តបន្ទាប់នូវទំនាក់ទំនងទ្វេភាគីប្រកបដោយភាតរភាព ដូចស្តែងឱ្យឃើញតាមរយៈការផ្លាស់ប្តូរទស្សនកិច្ចជាញឹកញាប់នៅគ្រប់កម្រិត និងបានឯកភាពគ្នាជំរុញបន្ថែមទៀតកិច្ចសហប្រតិបត្តិការដែលមានស្រាប់។ ភាគីទាំងពីរបានកត់សម្គាល់ដោយការពេញចិត្តចំពោះកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ចប្រកបដោយភាពធន់ រវាងកម្ពុជា និងសាធារណរដ្ឋកូរ៉េ ដោយបានបញ្ជាក់ឱ្យឃើញតាមរយៈការកើនឡើងខ្ពស់នូវទំហំពាណិជ្ជកម្មទ្វេភាគី ទោះបីជាមានវិបត្តិជំងឺកូវីដ-១៩ ក្តី។ ឯកឧត្តមឧបនាយករដ្ឋមន្ត្រី ប្រាក់ សុខុន មានសុទិដ្ឋិនិយមថា សកម្មភាពពាណិជ្ជកម្ម នឹងត្រូវបានជំរុញកាន់តែខ្លាំង នៅពេលដែលកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីកម្ពុជា-កូរ៉េ (CKFTA) ចូលជាធរមាន ។ ឯកឧត្តមឧបនាយករដ្ឋមន្ត្រី ប្រាក់ សុខុន ក៏បានកត់សម្គាល់ផងដែរថា សាធារណរដ្ឋកូរ៉េ បានឈរនៅលេខរៀងទី២ នៅក្នុងតារាងការវិនិយោគដោយផ្ទាល់ពីបរទេស (FDI) នៅកម្ពុជា ហើយការអនុវត្តកិច្ចព្រមព្រៀងភាពជាដៃគូសេដ្ឋកិច្ចគ្រប់ជ្រុងជ្រោយក្នុងតំបន់ (RCEP) នឹងដើរតួនាទីជាក្របខ័ណ្ឌក្នុងការជំរុញកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ចរវាងប្រទេសទាំងពីរ ។

ឯកឧត្តមឧបនាយករដ្ឋមន្ត្រី បានថ្លែងកោតសរសើរចំពោះតួនាទីរបស់សាធារណរដ្ឋកូរ៉េ ថាជាដៃគូអភិវឌ្ឍន៍ដ៏សំខាន់មួយរបស់កម្ពុជា និងបានថ្លែងអំណរសម្រាប់ជំនួយអភិវឌ្ឍដ៏ច្រើនជាបន្តបន្ទាប់របស់សាធារណរដ្ឋកូរ៉េសម្រាប់ការអភិវឌ្ឍសង្គម-សេដ្ឋកិច្ចកម្ពុជា រួមទាំងជំនួយក្នុងការប្រយុទ្ធប្រឆាំងនឹងជំងឺរាតត្បាតកូវីដ-១៩ ផងដែរ។ ក្នុងវិស័យដោះមីន ឯកឧត្តមឧបនាយករដ្ឋមន្ត្រី ប្រាក់ សុខុន បានអរគុណសមភាគីរបស់ឯកឧត្តម ចំពោះការរួមចំណែករបស់សាធារណរដ្ឋកូរ៉េដល់កិច្ចខិតខំ

អាសយដ្ឋាន: លេខ ៣ វិថី សម្តេច ហ៊ុន សែន
សង្កាត់ទន្លេបាសាក់ ខ័ណ្ឌចំការមន
រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ : (855) 23 216 122
ទូរសារ : (855) 23 216 141, 023 213 341
អ៊ីម៉ែល: mfaic@mfaic.gov.kh

ប្រឹងប្រែងក្នុងការដោះមីនដោយខ្លួនឯងរបស់កម្ពុជា និងការគាំទ្រដល់មជ្ឈមណ្ឌលតំបន់អាស៊ាន សម្រាប់សកម្មភាពមីន (ARMAC) ដែលមានការិយាល័យនៅរាជធានីភ្នំពេញ។

ក្នុងក្របខណ្ឌអាស៊ាន ឯកឧត្តម **ប៉ាក ជីន** បានអះអាងជាថ្មីអំពីការគាំទ្ររបស់សាធារណរដ្ឋកូរ៉េ ចំពោះភាពជាប្រធានអាស៊ានរបស់កម្ពុជានៅក្នុងឆ្នាំនេះ និងបានកោតសរសើរកិច្ចខិតខំប្រឹងប្រែង របស់កម្ពុជា ក្នុងឋានៈជាប្រធានអាស៊ាន ក្នុងការស្វែងរកដំណោះស្រាយប្រកបដោយសន្តិភាព សម្រាប់វិបត្តិនៅមីយ៉ាន់ម៉ា។ ពាក់ព័ន្ធនឹងកិច្ចសហប្រតិបត្តិការមេគង្គ-សាធារណរដ្ឋកូរ៉េ ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី បានសម្តែងការសោកស្តាយចំពោះការពន្យាពេលកិច្ចប្រជុំរដ្ឋមន្ត្រីការបរទេស មេគង្គ-សាធារណរដ្ឋកូរ៉េ លើកទី១២ និងបានស្នើឱ្យសម្របសម្រួលរកពេលវេលាសមស្របដើម្បី រៀបចំកិច្ចប្រជុំនាពេលអនាគត។

ភាគីទាំងពីរ ក៏បានធ្វើការផ្លាស់ប្តូរទស្សនៈគ្នាលើការវិវត្តនៅក្នុងតំបន់ និងអន្តរជាតិ រួមទាំង បញ្ហា ឧបទ្វីបកូរ៉េ ផងដែរ៕

រាជធានីភ្នំពេញ ថ្ងៃទី ០៥ ខែសីហា ឆ្នាំ២០២២

អ្នកនាំពាក្យក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ

**ជុំ សុន្ទរី**